DEPARTMENT OF HEALTH

# ព័ត៌មានអំពីជំងឺរលាកថ្លើមប្រភេទ B សម្រាប់អ្នកមានផ្ទៃពោះ

## តើអ្វីជាជំងឺរលាកថ្លើមប្រភេទ B?

- ជំងឺរលាកថ្លើមប្រភេទ B គឺជាជំងឺថ្លើម ដែលបណ្តាលពីវីរុស ។ មនុស្សជាច្រើនដែលកើតជំងឺរលាកថ្លើមប្រភេទ B គឺវីរុសនេះវាស្ថិតនៅក្នុងខ្លួនអ្នកជំងឺ ដែលបណ្តាលឲ្យមនុស្សនោះឈឺអស់មួយជីវិត ។
- ជំងឺរលាកថ្លើមប្រភេទ B អាចបង្កឲ្យមានបញ្ហាសុខភាពធ្ងន់ធ្ងរបន្តិចម្តងៗ បូករួមទាំងការខូចថ្លើម ខ្សោយថ្លើម និងធ្វើឲ្យកើតមហារីកថ្លើម ។
- មនុស្សភាគច្រើនដែលមានជំងឺរលាកថ្លើមប្រភេទ B មិនមានចេញរោគសញ្ញាទេ ហើយក៏អាចមិនដឹងខ្លួនថា គាត់កើតជំងឺនេះដែរ តែពួកគេនៅតែអាចចម្លងទៅអ្នកដទៃបាន។
- មនុស្សដែលមានផ្ទៃពោះ គួរធ្វើតេស្តជំងឺរលាកថ្លើមប្រភេទ B រាល់ពេលដែលខ្លួនមានផ្ទៃពោះ ។

## ហេតុអ្វីបានជាអ្នកមានផ្ទៃពោះត្រូវធ្វើតេស្តជំងឺនេះ?

- បើអ្នកមានផ្ទៃពោះ តេស្តជំងឺរលាកថ្លើម B ចេញវិជ្ជមាន គេត្រូវព្យាបាលទារក ចាប់ពីពេលកើត ។ ចំពោះទារកដែលទទួលបានការព្យាបាល នៅពេលកើត កម្រកើតជំងឺរលាកថ្លើម B ណាស់ ។
- នៅពេលទារកឆ្លងមេរោគរលាកថ្លើម B ពួកគេទំនងជាវិត្តទៅជាមេរោគពេញមួយជីវិត ។

## តើត្រូវធ្វើបែបណា បើអ្នកកើតជំងឺរលាកថ្លើមប្រភេទ B ហើយមានផ្ទៃពោះនោះ?

- ត្រូវពិភាក្សាបញ្ហានេះជាមួយនឹងគ្រូពេទ្យ ពីរបៀបគ្រប់គ្រងជំងឺរលាកថ្លើម B របស់អ្នក ។
- ពេទ្យមានរបៀបព្យាបាល ដែលអាចកាត់បន្ថយហានិភ័យ ពីការចម្លងមេរោគរលាកថ្លើម B ទៅកាន់ទារកក្នុងផ្ទៃ ។

## តើអ្នកអាចការពារទារកក្នុងផ្ទៃមិនឲ្យឆ្លងជំងឺនេះដោយរបៀបណា?

- បើអ្នកមិនដឹងថាតើក្នុងខ្លួនអ្នកមានមេរោគរលាកថ្លើម B ឬទេនោះ ត្រូវស្នើសុំគ្រូពេទ្យ ឲ្យចេញលិខិតឲ្យអ្នកធ្វើតេស្តឈាមរកមេរោគរលាកថ្លើម B ។
- បើលទ្ធផលតេស្តមេរោគរលាកថ្លើម B អវិជ្ជមាន អ្នកអាចសួរពេទ្យអំពីថ្នាំបង្ការជំងឺរលាកថ្លើម B ។
- បើលទ្ធផលតេស្តមេរោគរលាកថ្លើម B វិជ្ជមាន ពេទ្យត្រូវព្យាបាល និងតាមដានសុខភាពកូនរបស់អ្នក ៖
  - កូន របស់អ្នកនឹងទទួលបានការចាក់វ៉ាក់សាំងដូសដំបូង និងចាក់ថ្នាំ ក្លូប៊ុយលីន (HBIG) ប្រឆាំងនឹងមេរោគរលាកថ្លើម B ក្រោយពេលកើត ។
  - ហើយកូនរបស់អ្នក ត្រូវបន្តចាក់ថ្នាំបង្ការជំងឺរលាកថ្លើម B ជាបន្តបន្ទាប់ ឲ្យគ្រប់ចំនួនកំណត់ ។
  - ក្រោយកូនអ្នកទទួលបានថ្នាំបង្ការជំងឺនេះគ្រប់ចំនួនកំណត់ហើយ ពេទ្យនឹងបូមឈាមរបស់កូនអ្នក យកទៅពិនិត្យ ដើម្បីជាការបញ្ជាក់ថា កូនរបស់អ្នកមិនឆ្លងមេរោគរលាកថ្លើម B ។
- បើទោះបីជាអ្នកកើតជំងឺរលាកថ្លើម B ក៏ដោយ ក៏វាមិនមានគ្រោះថ្នាក់ដែរក្នុងការបំបៅកូនដោយទឹកដោះរបស់អ្នក ។



Minnesota Department of Health
Perinatal Hepatitis B Program
PO Box 64975
St. Paul, MN 55164-0975
651-201-5414, 1-877-676-5414
www.health.state.mn.us/hepatitis

01/31/2023

ដើម្បីស្នើសុំព័ត៌មាននេះ ក្នុងទម្រង់ទ្រាយផ្សេង សូមចុចទូរស័ព្ទទៅលេខ ៖ 651-201-5414